**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខ: ២៦៦ ប្រ.ក ប.ស្ត

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ព្រៃអណ្តូងដងផ្លិត» នៃដែនជម្រកសត្វព្រៃ «ឆែប» ស្ថិតនៅភូមិដងផ្លិត ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ឆែប»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.-**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងដងផ្លិត»** នៃដែនជម្រកសត្វព្រៃ «ឆែប» ស្ថិតនៅភូមិដងផ្លិត ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងដងផ្លិត»** នៃដែនជម្រកសត្វព្រៃ «ឆែប» មានផ្ទៃដីសរុបទំហំ **២៤២៨ ហិកតា** (ពីរពាន់បួនរយម្ភៃប្រាំបីហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 551652 | 1539125 | 12 | 556294 | 1540727 |
| 2 | 551417 | 1540015 | 13 | 556207 | 1540310 |
| 3 | 551435 | 1542796 | 14 | 555664 | 1539410 |
| 4 | 551849 | 1543335 | 15 | 555006 | 1538366 |
| 5 | 551984 | 1543952 | 16 | 554512 | 1538345 |
| 6 | 554709 | 1543805 | 17 | 554349 | 1538174 |
| 7 | 556826 | 1543555 | 18 | 554098 | 1538272 |
| 8 | 557195 | 1543603 | 19 | 553835 | 1538540 |
| 9 | 557087 | 1542411 | 20 | 553515 | 1538751 |
| 10 | 556947 | 1541918 | 21 | 553248 | 1539195 |
| 11 | 556393 | 1541524 | | | |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងដងផ្លិត»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងដងផ្លិត»** នៃដែនជម្រកសត្វព្រៃ «ឆែប» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងដងផ្លិត»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«ព្រៃអណ្តូងជងផ្លិត»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ចន្ទ ៥ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ព្រៃអណ្តូងដងផ្លិត ក្នុងដែនជម្រកសត្វព្រៃ ឆែប

## ភូមិសាស្ត្រ ភូមិដងផ្លិត ឃុំឆែបពីរ ស្រុកឆែប ខេត្តព្រះវិហារ

ឧបសម្ព័ន: ប្រកាសលេខ...៤៦៦...ចុះថ្ងៃទី...០៥...ខែ...សីហា...ឆ្នាំ២០១៨...របស់ក្រសួងបរិស្ថាន




និយាមកាព្រំប្រទល់សហគមន៍
តំបន់ការពារធម្មជាតិ ព្រៃអណ្តូងដងផ្លិត

| ID | X | Y |
|---|---|---|
| 1 | 551652 | 1539125 |
| 2 | 551417 | 1540015 |
| 3 | 551435 | 1542796 |
| 4 | 551849 | 1543335 |
| 5 | 551984 | 1543952 |
| 6 | 554709 | 1543805 |
| 7 | 556826 | 1543555 |
| 8 | 557195 | 1543603 |
| 9 | 557087 | 1542411 |
| 10 | 556947 | 1541918 |
| 11 | 556393 | 1541524 |
| 12 | 556294 | 1540727 |
| 13 | 556207 | 1540310 |
| 14 | 555664 | 1539410 |
| 15 | 555006 | 1538366 |
| 16 | 554512 | 1538345 |
| 17 | 554349 | 1538174 |
| 18 | 554098 | 1538272 |
| 19 | 553835 | 1538540 |
| 20 | 553515 | 1538751 |
| 21 | 553248 | 1539195 |

មាត្រដ្ឋាន: 1:50,000

0 0.5 1 2 Kilometers

Coordinate System: WGS 1984 UTM Zone 48N
MoE/ GIS Department

### កំណត់សំគាល់

N

- ចំណុចនិយាមការ
- ផ្លូវ
- ព្រំប្រទល់ដីសហគមន៍ស្នើសុំ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃឆែប